ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ: ៣៤៣៧/២០២៤.ប.ស្ថ អគត

ប្រកាស
ស្តីពី
ការជាក់ឱ្យអនុវត្តគោលការណ៍ណែនាំបច្ចេកទេស ស្តីពីការគណនាសំណងផលប៉ះពាល់ ពីការបំពុលប្រភពទឹកសាធារណៈ

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០/៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០/២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០/៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២/០៦១៨ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/២១/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០០៧/០៦២៣ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក

អគារមរតកតេជោ ដីឡូត៍លេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 213 908 / 023 220 369

- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៩ មាត្រា១១ មាត្រា១៧ និងតារាងឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ ឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- អនុក្រឹត្យលេខ ២៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- សារាចរលេខ ០៣ សរ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៥ ស្តីពីការទប់ស្កាត់ និងកាត់បន្ថយការបំពុលតំបន់ទឹកសាធារណៈ
- ប្រកាសអន្តរក្រសួង លេខ៨១០ ប្រក.បស្ដ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០២១ស្តីពីការកំណត់តម្លៃជាមូលដ្ឋាននៃធនធានធម្មជាតិ សម្រាប់ធ្វើការជួសជុលស្តារការខូចខាត
- ប្រកាសលេខ ៣០២ ប្រក.ប.ស្ដ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការអនុវត្តវិធានស្វ័យត្រួតពិនិត្យនៅតាមប្រភពបំពុលសក្តានុពល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

សម្រេច

ប្រការ ១.-

ប្រកាសនេះកំណត់អំពីការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំបច្ចេកទេស ស្តីពីការគណនាសំណងផលប៉ះពាល់ ពីការបំពុលប្រភពទឹកសាធារណៈ សំដៅជានាឱ្យមានប្រសិទ្ធភាពក្នុងការកាត់បន្ថយការបំពុលប្រភពទឹកសាធារណៈ។

ប្រការ ២.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពរបស់ម្ចាស់គម្រោង និងប្រតិបត្តិករដែលជាម្ចាស់ប្រភពបំពុលជាក់លាក់ ដែលបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានដោយផ្ទាល់ និងដោយប្រយោលដល់បរិស្ថាន សុខភាពសាធារណៈ សេដ្ឋកិច្ច សង្គម ជីវចម្រុះ និង ប្រព័ន្ធអេកូឡូស៊ី ។

ប្រការ ៣.-

គោលការណ៍ណែនាំបច្ចេកទេស ស្តីពីការគណនាសំណងផលប៉ះពាល់ ពីការបំពុលប្រភពទឹកសាធារណៈដោយផ្ទាល់ និងប្រយោល មានចែងក្នុងឧបសម្ព័ន្ធ នៃប្រកាសនេះ ។

ប្រការ ៤.-

គោលការណ៍ណែនាំបច្ចេកទេស ស្តីពីការគណនាសំណងផលប៉ះពាល់ ពីការបំពុលប្រភពទឹកសាធារណៈដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ អាចកែប្រែបានតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

ប្រការ ៥.

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៦.

អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងបរិស្ថានត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២៥

ឋ្លេមន្ត្រី

អ៊ាង សុជាតិ

កន្លែងទទួលៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៦ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ.៧៤.៣៣៧/ប្រ.ស.ប្ត.ក.ធ.ទ ចុះថ្ងៃទី.២៤.ខែ.ធ្នូ.ឆ្នាំ២០២៥
ត្រូវនឹងថ្ងៃ.អង្គារ.៣.កើត.ខែ.ជេស្ឋ.ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

គោលការណ៍ណែនាំបច្ចេកទេសស្តីពី ការគណនាសំណងផលប៉ះពាល់ ពីការបំពុលប្រភពទឹកសាធារណៈ

គោលការណ៍ណែនាំនេះកំណត់នីតិវិធី នៃការគណនាសំណងផលប៉ះពាល់ករណីការបំពុលប្រភពទឹកសាធារណៈ ដោយយោងទៅលើក្រមបរិស្ថាននិងធនធានធម្មជាតិ គន្ធីទី៣ កិច្ចគាំពារបរិស្ថាន មាតិកាទី៥ ការត្រួតពិនិត្យការបំពុលទឹក អនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យ និងអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា ៤ មាត្រា៩ មាត្រា១១ មាត្រា១៧ និងតារាងឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ ឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក។ គោលការណ៍ណែនាំនេះប្រើប្រាស់សម្រាប់គណនាសំណងផលប៉ះពាល់ផ្ទាល់ និងដោយប្រយោល ពីការបំពុលប្រភពទឹកសាធារណៈ។

១- សេចក្តីផ្តើម

ប្រភពបំពុលជាក់លាក់អាចបង្កផលប៉ះពាល់ដល់ប្រភពទឹកសាធារណៈ បើសិនការបញ្ចេញសំណល់រាវ ឬ ទឹកកខ្វក់ពីផលិតកម្ម អាជីវកម្ម និងសេវាកម្ម ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្ម ឬការធ្វើប្រព្រឹត្តិកម្មមិនបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ ការបញ្ចេញសំណល់រាវ ឬទឹកកខ្វក់មិនអនុលោមតាមកម្រិតកំណត់ស្តង់ដារ អាចបណ្តាលឱ្យមានការបំពុលប្រភពទឹកសាធារណៈ បង្កឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ សេដ្ឋកិច្ច សង្គម ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។

វិធីសាស្ត្រគណនា ដែលមានចែងក្នុងគោលការណ៍ណែនាំបច្ចេកទេសនេះនឹងអាចកំណត់នូវសំណងផលប៉ះពាល់ពីការបំពុលប្រភពទឹកសាធារណៈ ដែលបង្កឡើងដោយសកម្មភាពរបស់ម្ចាស់គម្រោង និងប្រតិបត្តិករ ដែលជាម្ចាស់ប្រភពបំពុលជាក់លាក់ ដោយមានវិសាលភាពអនុវត្តចំពោះសកម្មភាពរបស់ម្ចាស់គម្រោង និងប្រតិបត្តិករជាម្ចាស់ប្រភពបំពុលជាក់លាក់ ដែលបង្កឱ្យមានផលប៉ះពាល់អវិជ្ជមាន ដល់បរិស្ថាន សុខភាពសាធារណៈ សេដ្ឋកិច្ច សង្គម ជីវចម្រុះ និង ប្រព័ន្ធអេកូឡូស៊ី និងដើម្បីធានាឱ្យមានប្រសិទ្ធភាពក្នុងការកាតបន្ថយ ការបំពុលប្រភពទឹកសាធារណៈ និងបរិស្ថាន។

២- វិធីសាស្ត្រគណនាសំណងផលប៉ះពាល់ផ្ទាល់

ក- ការគណនាសំណងលើបន្ទុកបំពុលទឹក

ការគណនាផលប៉ះពាល់ផ្ទាល់លើបន្ទុកបំពុលទឹក ត្រូវបានកំណត់យកប៉ារ៉ាម៉ែត្រគុណភាពទឹកតម្រូវការអុកស៊ីសែនបៃបគីមី (COD) ឬ ប៉ារ៉ាម៉ែត្រផ្សេងទៀតក្នុងករណី COD មិនអាចយកជាការបានសម្រាប់ជាមូលដ្ឋានក្នុងការគណនាបន្ទុកបំពុល ដែលត្រូវផ្តល់សំណងផលប៉ះពាល់កើតពីការបញ្ចេញសំណល់រាវ

ឬទំហំសារធាតុបំពុលដែលមិនបានសម្អាត ធៀបជាមួយនឹងស្តង់ដារកំណត់តាមប្រភេទប្រភពទឹក ដែលទទួលរងការបំពុល។

ការគណនាសំណងលើបន្ទុកបំពុលត្រូវបានកំណត់ដូចខាងក្រោម៖

១. ករណីបង្ហូរចូលតំបន់ទឹកសាធារណៈប្រភេទទី១

$$F1 = \{[(C_{COD}-60)\times Q\times t]\div 1000000\}\times P$$

ដោយ៖

- F1 ថ្លៃលើការបង្ហូរសំណល់រាវមិនអនុលោមស្តង់ដារ គិតជា រៀល
- C_{COD} កំហាប់ COD របស់សំណល់រាវ ឬ ទឹកកខ្វក់ដែលត្រូវបានបញ្ចេញ គិតជា មីលីក្រាម/លីត្រ
- Q បរិមាណសំណល់រាវបញ្ចេញក្នុង១ថ្ងៃ គិតជា លីត្រ/ថ្ងៃ
- t រយៈពេលដែលក្រុមហ៊ុនបញ្ចេញសំណល់រាវ ឬ ទឹកកខ្វក់មិនអនុលោមស្តង់ដារ គិតជា ថ្ងៃ
- P តម្លៃសំណងពីការបញ្ចេញសំណល់រាវ ឬ ទឹកកខ្វក់ក្នុង១គីឡូក្រាមនៃ COD ស្មើនឹង ៨០០០រៀល/គីឡូក្រាម។

២. ករណីបង្ហូរចូលតំបន់ទឹកសាធារណៈប្រភេទទី២

$$F2 = \{[(C_{COD}-120)\times Q\times t]\div 1000000\}\times P$$

ដោយ៖

- F2 ថ្លៃលើការបង្ហូរសំណល់រាវមិនអនុលោមស្តង់ដារ គិតជារៀល
- C_{COD} កំហាប់ COD របស់សំណល់រាវ ឬ ទឹកកខ្វក់ដែលត្រូវបានបញ្ចេញ គិតជា មីលីក្រាម/លីត្រ
- Q បរិមាណសំណល់រាវបញ្ចេញក្នុង១ថ្ងៃ គិតជា លីត្រ/ថ្ងៃ
- t រយៈពេលដែលក្រុមហ៊ុនបញ្ចេញសំណល់រាវ ឬ ទឹកកខ្វក់មិនអនុលោមស្តង់ដារ គិតជា ថ្ងៃ
- P តម្លៃសំណងពីការបញ្ចេញសំណល់រាវ ឬទឹកកខ្វក់ក្នុង១គីឡូក្រាមនៃ COD ស្មើនឹង ៦០០០រៀល/គីឡូក្រាម។

៣. ករណីបង្ហូរចូលបណ្តាញលូភ្ជាប់ទៅស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់រួម

$$F3 = \{[(C_{COD}-300)\times Q\times t]\div 1000000\}\times P$$

ដោយ៖

- F3 ថ្លៃលើការបង្ហូរសំណល់រាវមិនអនុលោមស្តង់ដារ គិតជារៀល
- C_{COD} កំហាប់ COD របស់សំណល់រាវ ឬ ទឹកកខ្វក់ដែលត្រូវបានបញ្ចេញ គិតជា មីលីក្រាម/លីត្រ
- Q បរិមាណសំណល់រាវបញ្ចេញក្នុង១ថ្ងៃ គិតជា លីត្រ/ថ្ងៃ
- t រយៈពេលដែលក្រុមហ៊ុនបញ្ចេញសំណល់រាវ ឬ ទឹកកខ្វក់មិនអនុលោមស្តង់ដារ គិតជា ថ្ងៃ
- P តម្លៃសំណងពីការបញ្ចេញសំណល់រាវ ឬ ទឹកកខ្វក់ក្នុង១គីឡូក្រាមនៃ COD ស្មើនឹង ៤០០០រៀល/គីឡូក្រាម។

ខ- ការគណនាសំណងផលប៉ះពាល់លើសេដ្ឋកិច្ច សង្គម និងប្រព័ន្ធអេកូឡូស៊ី

ផលប៉ះពាល់នៃការបំពុលប្រភពទឹកសាធរណៈ ដោយការបង្ហូរសំណល់រាវពីប្រភពបំពុលជាក់លាក់លើសេដ្ឋកិច្ច សង្គម និងប្រព័ន្ធអេកូឡូស៊ី ត្រូវបានវាយតម្លៃជារួមតាមរយៈការចុះសិក្សានិងប្រមូលទិន្នន័យអំពីផលប៉ះពាល់លើការប្រើប្រាស់ទឹក ការបាត់បង់កម្លាំងពលកម្ម និងប្រាក់ចំណូល សុខភាពរបស់ប្រជាជន ធនធានជលផល/សត្វពាហនៈ ទិន្នផលប៉ះពាល់ស្រែចម្ការ ខូចខាតពីតំបន់ទេសចរណ៍ ការខូចខាត បាត់បង់ជីវៈចម្រុះក្នុងទឹក ស្មៅសមុទ្រ និងផ្កាថ្មជាដើម។

សំណងផលប៉ះពាល់ផ្ទាល់លើសេដ្ឋកិច្ច សង្គម និងប្រព័ន្ធអេកូឡូស៊ី ត្រូវបានគណនាដូចខាងក្រោមៈ

១. ការគណនាថ្លៃសំណងផលប៉ះពាល់លើការប្រើប្រាស់ទឹក

ត្រូវធ្វើការគណនាដោយផ្អែកលើបរិមាណធនធានទឹកដែលទទួលរងផលប៉ះពាល់ផ្ទាល់ ដោយការបង្ហូរសំណល់រាវ ឬ ទឹកកខ្វក់ពីទីតាំងប្រភពបំពុលជាក់លាក់ និងត្រូវបានគណនាតាមរូបមន្តដូចខាងក្រោមៈ

$$F4 = L \times W \times H \times Y$$

ដោយៈ

- F4 សំណងខូចខាតលើផ្ទៃទឹកដែលរងការបំពុល គិតជា រៀល
- L បណ្តោយប្រភពទឹកដែលរងការបំពុល គិតជា ម៉ែត្រ
- W ទទឹងប្រភពទឹកដែលរងការបំពុល គិតជា ម៉ែត្រ
- H ជម្រៅប្រភពទឹកដែលរងការបំពុល គិតជា ម៉ែត្រ
- Y មេគុណតម្លៃ គិតជា រៀល ស្មើនឹង ២០០រៀល/ម៉ែត្រត្រីគុណ។

២. ការគណនាសំណងខូចខាតនៃផលប៉ះពាល់លើការបាត់បង់កម្លាំងពលកម្ម និងប្រាក់ចំណូល

ត្រូវធ្វើការគណនាដោយផ្អែកលើចំនួនប្រជាជនសកម្មសរុប ដែលទទួលរងផលប៉ះពាល់ផ្ទាល់ដោយការបង្ហូរសំណល់រាវ ឬ ទឹកកខ្វក់ពីប្រភពបំពុលជាក់លាក់ និងត្រូវបានគណនាតាមរូបមន្តដូចខាងក្រោមៈ

$$F5 = I \times d \times n$$

ដោយៈ

- F5 សំណងខូចខាតលើការបាត់បង់កម្លាំងពលកម្មរបស់ប្រជាជន គិតជា រៀល
- I ប្រាក់ចំណូលជាមធ្យមក្នុងមួយថ្ងៃ គិតជា រៀល
- d ចំនួនថ្ងៃដែលមិនបានបំពេញការងារ គិតជា ថ្ងៃ
- n ចំនួនប្រជាជនរងផលប៉ះពាល់ផ្ទាល់សរុប គិតជា នាក់។

៣. ការគណនាសំណងផលប៉ះពាល់លើសុខភាពរបស់ប្រជាជន

ត្រូវបានគណនាដោយផ្អែកលើការចំណាយសម្រាប់ការព្យាបាលជំងឺ ដែលបង្កដោយការបង្ហូរសំណល់រាវ ឬ ទឹកកខ្វក់ពីប្រភពបំពុលជាក់លាក់ និងត្រូវបានគណនាតាមរូបមន្តដូចខាងក្រោមៈ

$$F6 = E \times n$$

ដោយៈ

- F6 សំណងលើការថែទាំសុខភាពរបស់ប្រជាជនរងផលប៉ះពាល់ផ្ទាល់ គិតជា រៀល

E ការចំណាយជាមធ្យមសម្រាប់ការព្យាបាល ក្នុងម្នាក់គិតជា រៀល
n ចំនួនប្រជាជនរងផលប៉ះពាល់ផ្ទាល់សរុប គិតជា នាក់។

៤. ការគណនាសំណងផលប៉ះពាល់លើធនធានជលផល មច្ឆជាតិ/សត្វ៣ហាន:

ត្រូវបានគណនាដោយផ្អែកលើចំនួនធនធានជលផល/សត្វ៣ហាន:សរុប ដែលទទួលរងផលប៉ះពាល់ផ្ទាល់ ដោយការបង្ហូរសំណល់រាវ ឬ ទឹកកខ្វក់ពីប្រភពបំពុលជាក់លាក់ និងត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម:

$$F7 = P \times f$$

ដោយ:

F7 សំណង គិតជា រៀល
P តម្លៃមធ្យម(តាមតម្លៃទីផ្សារជាក់ស្តែង) របស់ធនធានជលផល/សត្វ៣ហាន: ក្នុងមួយក្បាល ឬ គីឡូក្រាម គិតជា រៀល
f បរិមាណធនធានជលផល មច្ឆជាតិ/សត្វ៣ហាន: សរុបដែលរងផលប៉ះពាល់ គិតជាក្បាល ឬ គីឡូក្រាម។

៥. ការគណនាសំណងលើទិន្នផលប៉ះពាល់ស្រែ ចម្ការ

ត្រូវបានគណនាដោយផ្អែកលើទិន្នផលស្រែចម្ការដែលទទួលរងផលប៉ះពាល់ផ្ទាល់ ដោយការបង្ហូរសំណល់រាវ ឬ ទឹកកខ្វក់ពីប្រភពបំពុលជាក់លាក់ និងត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម:

$$F8 = R \times y \times t$$

ដោយ:

F8 សំណងផលប៉ះពាល់លើស្រែចម្ការ គិតជា រៀល
R តម្លៃមធ្យម (តាមតម្លៃទីផ្សារជាក់ស្តែង) គិតជា រៀល ក្នុងមួយ គីឡូក្រាម/តោន/ដើម/ហិកតា
y ទិន្នផលស្រែចម្ការដែលទទួលរងផលប៉ះពាល់ គិតជាគីឡូក្រាម/តោន/ដើម/ហិកតា
t ចំនួនដងនៃការប្រមូលផល។

៦. ការគណនាលើសំណងខូចខាតពីតំបន់ទេសចរណ៍

ត្រូវបានគណនាដោយផ្អែកលើចំនួនប្រជាជនសកម្មសរុប ដែលទទួលរងផល់ប៉ះពាល់ផ្ទាល់ពីការខូចខាតតំបន់ទេសចរណ៍ ដោយការបង្ហូរសំណល់រាវ ឬ ទឹកកខ្វក់ពីប្រភពបំពុលជាក់លាក់ និងត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម:

$$F9 = I \times d \times n$$

ដោយ:

F9 សំណងខូចខាតពីតំបន់ទេសចរ គិតជា រៀល
I ប្រាក់ចំណូលជាមធ្យមក្នុងមួយថ្ងៃ គិតជា រៀល
d ចំនួនថ្ងៃដែលមិនបានបំពេញការងារ គិតជា ថ្ងៃ
n ចំនួនប្រជាជនរងផលប៉ះពាល់ផ្ទាល់សរុប គិតជា នាក់។

៧. ការគណនាសំណងផលប៉ះពាល់លើអចលនទ្រព្យ

ត្រូវបានគណនាដោយផ្អែកលើការធ្លាក់ចុះតម្លៃអចលនទ្រព្យក្នុងតំបន់ទទួលរងផលប៉ះពាល់ដោយការបង្ហូរសំណល់រាវ ឬ ទឹកកខ្វក់ពីប្រភពបំពុលជាក់លាក់ និងត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

$$F11 = S \times P$$

ដោយ៖

F11 សំណងផលប៉ះពាល់លើតម្លៃអចលនទ្រព្យ គិតជា រៀល

S ចំនួនឬទំហំអចលនទ្រព្យប៉ះពាល់សរុប គិតជា ហិកតា/ខ្នងផ្ទះ/Unit

P តម្លៃធ្លាក់ចុះនៃអចលនទ្រព្យ (ប្រែប្រួលតាមតម្លៃទីផ្សារជាក់ស្តែង) រៀល ក្នុងមួយហិកតា/ខ្នងផ្ទះ/Unit។

៨. ការគណនាសំណងលើការខូចខាត បាត់បង់ដីរៈចម្រុះ ដើមឈើ ព្រៃឈើ សត្វព្រៃ ស្មៅសមុទ្រ ផ្កាថ្ម

ត្រូវបានគណនាដោយផ្អែកលើផ្ទៃក្រឡា ឬចំនួន នៃការបាត់បង់ ឬ ខូចខាតដីរៈចម្រុះ ដើមឈើ ព្រៃឈើ សត្វព្រៃ /ស្មៅសមុទ្រ/ផ្កាថ្ម ដោយការបង្ហូរសំណល់រាវ ឬ ទឹកកខ្វក់ពីប្រភពបំពុលជាក់លាក់ និងត្រូវបានគណនាតាមរូបមន្តដូចខាង៖

$$F10 = S \times P$$

ដោយ៖

F10 សំណងខូចខាតលើដីរៈចម្រុះ ដើមឈើ ព្រៃឈើ សត្វព្រៃ ស្មៅសមុទ្រ ផ្កាថ្ម /ស្មៅសមុទ្រ/ផ្កាថ្ម គិតជា រៀល

S ផ្ទៃដី ឬចំនួន ខូចខាត/បាត់បង់សរុប គិតជា ហិកតា/ដើម/ក្បាល/គីឡូ

P តម្លៃនៃការនៃការបាត់បង់ ឬ ខូចខាត ជាឯកតា យោងតាមប្រកាសអន្តរក្រសួង លេខ ៤១០ ប្រក.បស្ថ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០២១ស្តីពីការកំណត់តម្លៃជាមូលដ្ឋាននៃធនធានធម្មជាតិ សម្រាប់ធ្វើការជួសជុលស្តារការខូចខាត។

៣- វិធីសាស្ត្រគណនាផលប៉ះពាល់ដោយប្រយោល

ការគណនាផលប៉ះពាល់ដោយប្រយោល ត្រូវត្រួតពិនិត្យ និងវាយតម្លៃផលប៉ះពាល់ទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ ធនធានសេដ្ឋកិច្ច សង្គម និងការស្តារបរិស្ថានឡើងវិញ ដូចខាងក្រោម៖

ក- ការគណនាសំណងលើការបាត់បង់ ឬ ខូចខាតព្រៃឈើ/ព្រៃកោងកាង

ត្រូវបានគណនាដោយផ្អែកលើតម្លៃកាបូនស្តុក ត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

$$F12 = TC \times P$$

ដោយ៖

F12 សំណងខូចខាត តម្លៃកាបូនស្តុក គិតជា រៀល

TC កាបូនស្តុកសរុប គិតជា តោន = AGB x CF

P តម្លៃសម្រាប់ការខាតបង់ គិតជា រៀល/តោន

AGB Above-Ground Biomass (ជីវម៉ាសលើដី) គិតជា តោន/ហិកតា

CF Carbon Fraction of the biomass (ប្រភាគកាបូននៃជីវម៉ាស) (0.៤៧ ទៅ 0.៥0 អាស្រ័យទៅតាមប្រភេទព្រៃឈើ និងដំណាំ)។

ខ- ការគណនាសំណងខូចខាតប្រយោលលើសុខភាពសាធារណៈ/សុខភាពប្រជាពលរដ្ឋ

ត្រូវបានគណនាដោយផ្អែកលើការចំណាយសម្រាប់ព្យាបាលជំងឺរបស់អ្នកទទួលរងផលប៉ះពាល់ដោយប្រយោល ដែលកើតមានឡើងក្នុងកំឡុងពេលទទួលរងនូវផលប៉ះពាល់ និងសម្រាប់អនាគតក្នុងករណីមិនទាន់មានការលេចចេញនូវជំងឺ និងត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

$$F14 = N \times P \times T$$

ដោយ៖

F14 សំណងខូចខាតប្រយោលលើសុខភាពសាធារណៈ គិតជា រៀល

N ចំនួនអ្នកទទួលរងផលប៉ះពាល់

P តម្លៃចំណាយលើការព្យាបាលជាក់ស្តែង

T រយៈពេលនៃការព្យាបាល។

សន្និដ្ឋាន៖

ជារួមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគណនាសំណងផលប៉ះពាល់ ពីការបំពុលប្រភពទឹកសាធារណៈនេះ គឺសម្រាប់វាយតម្លៃការខូចខាតបរិស្ថាន ដែលបណ្តាលមកពីការបញ្ចេញរាវដែលមិនបានសម្អាតឱ្យបានត្រឹមត្រូវតាមស្តង់ដារ ដែលជាការបង្ហាញពីតម្រូវការសម្រាប់ការការពារបរិស្ថានប្រកបដោយប្រសិទ្ធភាព និងស្របតាមក្របខ័ណ្ឌច្បាប់ដ៏រឹងមាំ។ ខណៈពេលដែលការអនុវត្តគោលណែនាំបច្ចេកទេសនេះ អាចជួយកាត់បន្ថយការបំពុល ជាពិសេសការបង្កើនសំណល់រាវឧស្សាហកម្ម និងជំរុញការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលជាវិធីសាស្ត្រក្នុងគិតគូរពីលក្ខខណ្ឌបច្ចេកទេស និងបទដ្ឋានគតិយុត្ត ព្រមទាំងបង្ហាញពីភាពជាក់លាក់នៃគណនាការខូចខាត ដែលតម្រូវឱ្យមានការស្តារបរិស្ថានឡើងវិញផងដែរ។